**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តព្រះវិហារ**

លេខ ៤១៧/១៦ សជណ

ធ្វើនៅខេត្តព្រះវិហារ,ថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង

## ស្តីពី

## ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៧

រដ្ឋបាលខេត្តព្រះវិហារ សូមជម្រាបជូនដល់អ្នកទទួលការទាំងអស់ឲ្យបានជ្រាបថា រដ្ឋបាលខេត្តនឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៧ ដើម្បីដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧ ដោយចាប់ផ្តើមទទួលពាក្យសុំចុះឈ្មោះអ្នកទទួលការ ឬដាក់ពាក្យជាថ្មីឡើងវិញ គិតចាប់ថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី០៧ខែតុលា ឆ្នាំ២០១៦ វេលា ម៉ោង ៥:៣០នាទីល្ងាច ។ អ្នកទទួលការ ដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ មានសិទ្ធិដាក់សំណើដេញថ្លៃ គម្រោងមូលនិធិឃុំ សង្កាត់ នៅគ្រប់ឃុំ សង្កាត់ ទូទាំងព្រះរាជាណាចក្រកម្ពុជា។

អ្នកទទួលការត្រូវបានបែងចែកជាបីប្រភេទ៖

-ប្រភេទទី១៖ អ្នកទទួលការសំណង់ទូទៅ(ការងារសំណង់អគារ និងការងារបេតុ ...។ល។)

-ប្រភេទទី២៖ អ្នកទទួលការការងារដី (ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវក្រាលក្រួសក្រហម ...។ល។)

-ប្រភេទទី៣៖ អ្នកទទួលការឯកទេស ( អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេសសម្រាប់ការងារ ឧទាហរណ៍ អណ្តូងស្នប់ ...។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារបរិក្ខារគ្រប់គ្រាន់ដូចមានបរិយាយនៅក្នុងពាក្យស្នើសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ ហើយត្រូវមានបទពិសោធន៍អនុវត្តគម្រោងទាក់ទងនឹងប្រភេទនីមួយៗ ដែលបានស្នើសុំយ៉ាងតិច០២ក្នុងអំឡុងពេល ៥ឆ្នាំចុងក្រោយ ។ អនុគណៈកម្មការបុរេលក្ខណសម្បត្តិ នឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនអ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការជាមួយម្ចាស់គម្រោង ដោយផ្អែកលើកំណត់ត្រាកន្លងមក ។ លទ្ធផលនៃការវាយតម្លៃនេះ អនុគណៈកម្មការបុរេលក្ខណសម្បត្តិនឹងដាក់ជូនអភិបាលខេត្ត ដើម្បីពិនិត្យ និងសម្រេច ។ អ្នកទទួលការទាំងឡាយណាដែលត្រូវបានរកឃើញថា មានការពាក់ព័ន្ធនឹងការឃុបឃិតស៊ុំគ្រលំគ្នាការក្លែងបន្លំ និងអំពើពុករលួយ ហើយចាប់ពីពេលដែលត្រូវបានដកសិទ្ធិជាផ្លូវការ អ្នកទទួលការនោះ នឹងមិនត្រូវបានពិចារណាក្នុងការបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកទទួលការឡើយ។

អាស្រ័យហេតុនេះ បើអ្នកទទួលការមានបំណងចុះបញ្ជីឈ្មោះអ្នកទទួលការ សូមរួសរាន់មកដាក់ពាក្យនៅទីចាត់ការផែនការ និងវិនិយោគសាលាខេត្ត តាមកាលបរិច្ឆេទដែលបានកំណត់ខាងលើ ។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការឆ្នាំកន្លងមក ក៏ត្រូវដាក់ពាក្យជាថ្មីឡើងវិញដែរ ដោយមកយកពាក្យ

សុំចុះឈ្មោះនៅទីចាត់ការផែនការ និងវិនិយោគ ដែលមានទីតាំងនៅក្នុងបរិវេណសាលាខេត្តព្រះវិហារ ដោយឥតបង់ថ្លៃ ឬអាចទាញយកពីក្នុងគេហទំព័ររបស់ គ.ជ.អ.ប (www.ncdd.gov.kh)។

ត.ប.អភិបាលខេត្ត

នាយករដ្ឋបាល

មុត តិសិរ្ថនា

**ចម្លងជូន**

-អគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងមហាផ្ទៃ

-លេខាធិការដ្ឋានគ.ជ.អ.ប

-ឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត

(ដើម្បីជូនជ្រាប)

-ឯកសារ-កាលប្បវត្តិ